ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អគ្គនាយកដ្ឋានការងារ
នាយកដ្ឋានអធិការកិច្ចការងារ
លេខ:......៦៧២៤......កប/អក/អធក

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៣

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**
**ជម្រាបមក**
**លោកនាយកក្រុមហ៊ុន** CHANG TAI INTERNATIONAL CORP

**កម្មវត្ថុ:** ការធ្វើការបន្ថែមម៉ោង

**យោង** : លិខិតរបស់លោកគ្មានលេខ: ចុះថ្ងៃទី ០១ខែកញ្ញា ឆ្នាំ២០១៣

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកនាយកបានជ្រាបថា នាយកដ្ឋានអធិការកិច្ចការងារមិនយល់ទាស់ទេ ចំពោះការស្នើសុំធ្វើការបន្ថែមម៉ោងរបស់ក្រុមហ៊ុនលោក ដែលមានការមមាញឹកក្នុងការជំរុញការងារឲ្យទាន់តាមសំណូមពររបស់អតិថិជន។ ដើម្បីធានាដល់សុខភាពរបស់កម្មករនិយោជិត នាយកដ្ឋានអធិការកិច្ចការងារ អនុញ្ញាតឲ្យក្រុមហ៊ុនរបស់លោកធ្វើការបន្ថែមម៉ោងចំនួន០២ ម៉ោងក្នុងមួយថ្ងៃ ដែលមានរយៈពេល០២ខែដោយគិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ ថ្ងៃទី៣១ខែតុលាឆ្នាំ២០១៣។

ម៉្យាងវិញទៀត ការដាក់ឲ្យធ្វើការលើសម៉ោង ត្រូវអនុវត្តតាមការស្ម័គ្រចិត្តគឺមិនត្រូវបង្ខិតបង្ខំកម្មករនិយោជិតណាម្នាក់ ដែលគេមិនចង់ធ្វើការបន្ថែមម៉ោងឡើយ។ ក្រុមហ៊ុនត្រូវផ្តល់ប្រាក់ថ្លៃបាយចំនួន ២០០០រៀល ក្នុងមួយថ្ងៃ ឬត្រូវផ្តល់បាយមួយពេលដោយឥតគិតថ្លៃ ជូនចំពោះកម្មករនិយោជិតណាដែលបានស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង។

ចំពោះប្រាក់ឈ្នួលធ្វើការលើសម៉ោង ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមឧបសម្ព័ន្ធជូនជាប់ជាមួយនេះ។

អាស្រ័យហេតុដូចនេះ សូមលោកនាយកអនុវត្តឲ្យបានត្រឹមត្រូវតាមការណែនាំខាងលើ និងបិទផ្សាយឲ្យកម្មករនិយោជិតបានដឹងទាំងអស់គ្នា៕

អ៊ិន-ខេមរា